ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ៣១១ ក.ប/អ.ត.ន

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៦

# លិខិតអំពាវនាវ

ដើម្បីអបអរសាទរ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៣-១៤ និង១៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ខាងមុខនេះ ខ្ញុំមានកិត្តិយស សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ជ្រាបថា ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានទូក ង ចំនួន ០៥គ្រឿង ដើម្បីចូលរួមប្រកួត ដូចមានរាយឈ្មោះខាងក្រោម៖

| | | |
|---|---|---|
| ១-ទូក ង ឈ្មោះ | សំហេងសែនជ័យបារមីចាក់អង្រែលើ | ចំណុះ៦៥នាក់ បម្រុង១៥នាក់ សរុប៨០នាក់ (រាជធានីភ្នំពេញ) |
| ២-ទូក ង ឈ្មោះ | បាសាក់សំហេងសែនជ័យ | ចំណុះ៦៥នាក់ បម្រុង១៥នាក់ សរុប៨០នាក់ (រាជធានីភ្នំពេញ) |
| ៣-ទូក ង ឈ្មោះ | សំហេងសែនតេជៈបារមីក្តីដូង | ចំណុះ៦៥នាក់ បម្រុង១៥នាក់ សរុប៨០នាក់ (រាជធានីភ្នំពេញ) |
| ៤-ទូក ង ឈ្មោះ | សំហេងសែនជ័យបារមីទួលទំពូង | ចំណុះ៦៥នាក់ បម្រុង១៥នាក់ សរុប៨០នាក់ (រាជធានីភ្នំពេញ) |
| ៥-ទូក ង ឈ្មោះ | សំហេងសែនតេជៈបារមីសារាវន្តតេជោ | ចំណុះ២៥នាក់ បម្រុង៥នាក់ សរុប៣០នាក់ (រាជធានីភ្នំពេញ) |
| | | សរុប = ៣៥០នាក់ |

អាស្រ័យហេតុនេះ ខ្ញុំសូមអំពាវនាវដល់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី មេត្តាជួយឧបត្ថម្ភជាថវិកា ឬសម្ភារៈដូចជា ខោ អាវ មួក និងគ្រឿងឧបភោគ បរិភោគ ទឹកបរិសុទ្ធ ជាដើម ដើម្បីលើកទឹកចិត្តកីឡាករទូក ង ទាំង០៥គ្រឿង ដូចមានរាយឈ្មោះខាងលើ។

សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី បានទទួលនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

សូមទំនាក់ទំនង៖

| | |
|---|---|
| -ឯ.ឧ ហេង សួរ | 012 693 777 |
| -ឯ.ឧ សេង សក្តា | 088 882 8888 |
| -ឯ.ឧ ប្រាក់ ចាន់ធឿន | 012 664 454 |
| -ឯ.ឧ ឡៅ ហ៊ីម | 012 855 530 |
| -ឯ.ឧ សឹង ម៉ុន | 012 417 400 |
| -លោក ហាំង តុលា | 012 706 070 |